# គោលការណ៍សមាជិកភាព
# នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

## ក្រុមប្រឹក្សាភិបាលនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាត

- បានឃើញលក្ខន្តិកៈសមាគមផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ចុះថ្ងៃទី២៥ ខែ មេសា ឆ្នាំ ២០១២
- យោងយោបល់ពីសមាជិកសមាគមក្នុងកិច្ចប្រជុំសន្និបាតប្រចាំឆ្នាំ ២០១៤ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤
- យោងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ក្នុងកិច្ចប្រជុំថ្ងៃទី១៣ ខែកម្ភៈ ឆ្នាំ ២០១៥
- យោងតាមការសម្រេចរបស់អង្គសន្និបាតវិសាមញ្ញនៃការធ្វើវិសោធនកម្មលក្ខន្តិកៈសមាគមសម្រាប់នីតិបុគ្គលកាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១
- យោងតាមប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ២៩០១ ប្រក សម្រេចឱ្យចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១

## <u>សម្រេច</u>

**ប្រការ ១. សមាជិកភាព** (យោងតាមប្រការ ៩ នៃលក្ខន្តិកៈ)

សមាគម មានសមាជិក បីប្រភេទ គឺសមាជិកស្ថាបនិក សមាជិកអាជីព និងសមាជិកគាំទ្រ។

- សមាជិកស្ថាបនិក គឺជាបុគ្គលដែលបានចូលរួមផ្ដួចផ្ដើមគំនិតបង្កើតសមាគមនេះឡើងដោយបានចំណាយឧបត្ថម្ភសម្ភារ និងថវិកាដើម្បីឱ្យសមាគមបានដំណើរការដោយស្របច្បាប់។
- **សមាជិកអាជីព** (ពីមុនសមាជិកសកម្ម) គឺនីតិបុគ្គល ឬ រូបវន្តបុគ្គល ឬជាម្ចាស់សហគ្រាស ជាអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដែលបានទទួលប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ពីមុនក្រសួងឧស្សាហកម្ម និងសិប្បកម្ម) ដែលបានស្នើសុំ និងទទួលបានការអនុម័តឱ្យចូលជាសមាជិកអាជីពរបស់សមាគមដោយក្រុមប្រឹក្សាភិបាល។ សមាជិកអាជីពមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតជាសមាសភាពក្រុមប្រឹក្សាភិបាលរបស់សមាគម។
- **សមាជិកគាំទ្រ** (ពីមុនសមាជិកសាមញ្ញ) គឺជាសមាជិកដែលបានចូលរួមផ្ដល់នូវមូលនិធិ សម្ភារ បទពិសោធន៍ ឬមានស្នាដៃជួយសមាគមឱ្យមានការរីកចម្រើន ដែលអាចជានីតិបុគ្គល ឬរូបវន្តបុគ្គល ឬជាម្ចាស់សហគ្រាស ដែលពាក់ព័ន្ធការងារវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា អ្នកផ្គត់ផ្គង់សម្ភារ និង

វត្ថុធាតុដើមគីមីសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ ក្រុមហ៊ុនផ្តល់សេវាកម្ម ឬដៃគូអភិវឌ្ឍន៍ជាដើម។ ទន្ទឹមនឹងនេះ សមាគមបើកទូលាយចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានវិជ្ជាជីវៈផ្នែកទឹកស្អាត ក៏អាចចូលជាសមាជិកគាំទ្រផងដែរ។ សមាជិកគាំទ្រគ្មានសិទ្ធិបោះឆ្នោត និងគ្មានឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាភិបាលរបស់សមាគមឡើយ ប៉ុន្តែអាចចូលរួម និងបញ្ចេញមតិយោបល់នៅក្នុងកិច្ចប្រជុំ និងសន្និបាតរបស់សមាគម។

- **សមាជិកអាជីព និងសមាជិកគាំទ្រ** អាចចាត់តំណាងម្នាក់ ឬច្រើននាក់ដើម្បីចូលរួមក្នុងកិច្ចប្រជុំ និងសន្និបាតរបស់សមាគម ប៉ុន្តែសមាជិកអាជីពមួយអាចមានសំឡេងបោះឆ្នោតបានតែមួយប៉ុណ្ណោះ។

**ប្រការ ២. ការចូលជាសមាជិក** (យោងប្រការ ១០ និង១១ នៃលក្ខន្តិកៈសមាគម)

ការស្នើសុំចូលជាសមាជិករបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្ត។ បុគ្គល ដែលមានបំណងសុំចូលជាសមាជិករបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ត្រូវដាក់ពាក្យសុំចូលជាសមាជិករបស់សមាគមទៅគណៈកម្មាធិការប្រតិបត្តិ និងត្រូវបំពេញនូវលក្ខខណ្ឌចាំបាច់មួយចំនួនខាងក្រោម៖

- ស្ម័គ្រចិត្តដាក់ពាក្យសុំចូលជាសមាជិក និងបំពេញកាតព្វកិច្ចសមាជិកភាព
- ជារូបវន្តបុគ្គលដែលមានអាយុចាប់ពី១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ ឬនីតិបុគ្គលដែលបានចុះបញ្ជីជាមួយស្ថាប័នមានសមត្ថកិច្ច ស្របតាមច្បាប់ពាក់ព័ន្ធ នៃព្រះរាជាណាចក្រកម្ពុជា
- ទទួលបាននូវប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ពីមុនក្រសួងឧស្សាហកម្ម និងសិប្បកម្ម) សម្រាប់ការសុំចូលជាសមាជិកអាជីព
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាប់ពិរុទ្ធពីបទមជ្ឈឹម ឬបទឧក្រិដ្ឋណាមួយ។

ការសម្រេចលើការស្នើសុំចូលជាសមាជិករបស់សមាគម ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល ដោយសេចក្តីសម្រេចតាមរយៈសំឡេង ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនកូរ៉ុមចូលរួម ២/៣ (ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលត្រូវរៀបចំបែបបទ នីតិវិធី លក្ខខណ្ឌលម្អិត និងគំរូពាក្យសុំចូលជាសមាជិករបស់សមាគម ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

សមាជិកអាជីព និងសមាជិកគាំទ្រ មានកាតព្វកិច្ចបង់ប្រាក់វិភាគទានសមាជិកភាពប្រចាំឆ្នាំតាមការកំណត់។ ការបង់វិភាគទាននេះ អាចបង់ប្រាំមួយខែម្តង។

ក្រុមប្រឹក្សាភិបាល ត្រូវកំណត់ថ្លៃវិភាគទានសមាជិកភាព និងអាចការកែប្រែថ្លៃវិភាគទាននេះបានតាមការចាំបាច់ ដោយសេចក្តីសម្រេចតាមរយៈសំឡេង ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនកូរ៉ុមចូលរួម ២/៣(ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល។

**ប្រការ ៣. សិទ្ធិរបស់សមាជិក** (យោងប្រការ ៩ នៃលក្ខន្តិកៈសមាគម)

សមាជិកអាជីព មានសិទ្ធិក្នុងការបោះឆ្នោតនៅគ្រប់ការប្រជុំសន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញបាន ដោយឡែកសមាជិកគាំទ្រ គ្មានសិទ្ធិបោះឆ្នោតទេ ប៉ុន្តែអាចចូលរួម និងបញ្ចេញមតិយោបល់បាននៅគ្រប់ការប្រជុំសន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញ។

## ប្រការ ៤. វិភាគទានសមាជិក

សមាជិកសមាគមទាំងអស់ មានកាតព្វកិច្ចបង់ថ្លៃវិភាគទានសមាជិកភាពសមាគម ប្រចាំឆមាស ឬប្រចាំឆ្នាំ ដើម្បីទ្រទ្រង់ការងាររបស់សមាគម។ វិភាគទានសមាជិក ត្រូវបានកំណត់តាមប្រភេទសមាជិកភាព និងទំហំអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដូចខាងក្រោម៖

1. សមាជិកគាំទ្រជារូបវន្តបុគ្គលត្រូវបង់វិភាគទានក្នុង១ឆ្នាំយ៉ាងតិច $៥០ (ហាសិបដុល្លារ)
2. សមាជិកគាំទ្រជានីតិបុគ្គលខ្មែរ ត្រូវបង់វិភាគទានក្នុង១ឆ្នាំយ៉ាងតិច $២០០ (ពីររយដុល្លារ)
3. សមាជិកគាំទ្រជានីតិបុគ្គលបរទេស ត្រូវបង់វិភាគទានក្នុង១ឆ្នាំយ៉ាងតិច $៣០០ (បីរយដុល្លារ)
4. សមាជិកអាជីព ជាអ្នកផ្គត់ផ្គង់ទឹកស្អាតខ្នាតតូច ដែលមានចំនួនតំណរតិចជាង ឬស្មើនឹង ៧៥០ តំណ ត្រូវបង់វិភាគទានក្នុង១ឆ្នាំយ៉ាងតិច $១៣០ (មួយរយសាមសិបដុល្លារ)
5. សមាជិកអាជីព ជាអ្នកផ្គត់ផ្គង់ទឹកស្អាតខ្នាតតូចល្មម ដែលមានចំនួនតំណរចាប់ពី ៧៥១ តំណ ដល់ ១៥០០ តំណ ត្រូវបង់វិភាគទានក្នុង១ឆ្នាំយ៉ាងតិច $១៨០ (មួយរយប៉ែតសិបដុល្លារ)
6. សមាជិកអាជីព ជាអ្នកផ្គត់ផ្គង់ទឹកស្អាតខ្នាតមធ្យម ដែលមានចំនួនតំណរចាប់ពី ១៥០១ តំណ ដល់ ៣០០០ តំណ ត្រូវបង់វិភាគទានក្នុង១ឆ្នាំយ៉ាងតិច $៣០០ (បីរយដុល្លារ)
7. សមាជិកអាជីព ជាអ្នកផ្គត់ផ្គង់ទឹកស្អាតខ្នាតធំ ដែលមានចំនួនតំណរច្រើនជាង ៣០០០ តំណ ត្រូវបង់វិភាគទានក្នុង១ឆ្នាំយ៉ាងតិច $៥០០ (ប្រាំរយដុល្លារ)

សមាជិកដែលបានបង់វិភាគទានប្រចាំឆ្នាំច្រើនជាងចំនួនអប្បរមា ដែលបានកំណត់ខាងលើ នឹងអាចទទួលបានចំនួនអ្នកតំណាងម្នាក់បន្ថែមទៀតសម្រាប់ទទួលផលប្រយោជន៍សមាជិកភាព រៀងរាល់ប្រាក់វិភាគទានចំនួន $១០០ (មួយរយដុល្លារ) លើសប្រាក់វិភាគទានអប្បរមា។

សម្រាប់សមាជិកថ្មី ការបង់វិភាគទានសមាជិកសម្រាប់គឺ ឆ្នាំទី១ ត្រូវតំណត់អាស្រ័យនឹងពេលវេលាចូលសមាជិកដូចខាងក្រោម៖

- ចូលក្នុងត្រីមាសទី១ (ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែមីនា) ត្រូវបង់វិភាគទាន ១០០%
- ចូលក្នុងត្រីមាសទី២ (ពីថ្ងៃទី១ ខែមេសា ដល់ ថ្ងៃទី៣០ ខែមិថុនា) ត្រូវបង់វិភាគទាន ៧៥%
- ចូលក្នុងត្រីមាសទី៣ (ពីថ្ងៃទី១ ខែកក្កដា ដល់ ថ្ងៃទី៣០ ខែកញ្ញា) ត្រូវបង់វិភាគទាន ៥០%
- ចូលក្នុងត្រីមាសទី៤ (ពីថ្ងៃទី១ ខែតុលា ដល់ ថ្ងៃទី៣១ ខែធ្នូ) ត្រូវបង់វិភាគទាន ២៥%

បើសមាជិកចូលចាប់ពីត្រីមាសទី២ នោះតម្រូវឱ្យបង់ប្រាក់វិភាគទានសម្រាប់ឆ្នាំ១ និងឆ្នាំទី២។

## ប្រការ ៥. អត្ថប្រយោជន៍របស់សមាជិក

សមាជិកទាំងអស់របស់សមាគមនឹងទទួលបាន អត្ថប្រយោជន៍ដូចខាងក្រោម៖

| អត្ថប្រយោជន៍សមាជិក | សមាជិកគាំទ្រ | | សមាជិកអាជីព | | | |
|---|---|---|---|---|---|---|
| | រូបវន្តបុគ្គល | នីតិបុគ្គល | តូច | តូចល្មម | មធ្យម | ធំ |
| ការភ្ជាប់ទំនាក់ទំនងក្នុងបណ្តាញសមាគម* | | | | | | |
| ចុះឈ្មោះក្នុងសៀវភៅសមាជិកសមាគម | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ចុះក្នុងបញ្ជីអ្នកផ្គត់ផ្គង់សម្ភារៈ និងសេវាកម្ម | ✓ | ✓ | - | - | ✓ | ✓ |
| ចូលមើលក្នុងគេហទំព័រសម្រាប់តែសមាជិកសមាគម | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | |
|---|---|---|---|---|---|---|
| 💧 ទទួលបានព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| 💧 មានអ្នកតំណាងដែលអាចទទួលបានអត្ថប្រយោជន៍ពីសមាជិកភាព** | ១នាក់ | ២នាក់ | ១នាក់ | ១នាក់ | ២នាក់ | ១នាក់ |
| 💧 ទទួលបានព័ត៌មានថ្មីៗទាក់ទងនឹងវិស័យទឹកស្អាត | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| 💧 ចូលរួមមហាសន្និបាតប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| **ការសហការ*** | | | | | | |
| 💧 អាចសុំចូលជាសមាជិកក្រុមប្រឹក្សាយោបល់របស់សមាគម | - | ✓ | - | - | ✓ | ✓ |
| 💧 អាចសុំចូលរួមក្នុងក្រុមការងារជំនាញទឹកស្អាត | - | ✓ | - | - | ✓ | ✓ |
| 💧 ប្រឹក្សាយោបល់លើបញ្ហា ច្បាប់ អាជីវកម្ម ឬបច្ចេកទេស | - | ✓ | ✓ | ✓ | ✓ | ✓ |
| 💧 អាចសុំចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍ជាមួយដៃគូអភិវឌ្ឍន៍ | - | ✓ | ✓ | ✓ | ✓ | ✓ |
| 💧 ចូលរួមសន្និសិទ្ធទឹកប្រចាំឆ្នាំ និងកិច្ចប្រជុំផ្សេងៗ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| 💧 អាចសុំឱ្យចុះស្ទង់ពីតម្រូវការ ការអភិវឌ្ឍសមត្ថភាព | - | ✓ | ✓ | ✓ | ✓ | ✓ |
| 💧 អាចសុំចូលរួមការបណ្តុះបណ្តាលបច្ចេកទេសក្នុងវិស័យទឹកស្អាត | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| 💧 អាចទទួលបានការចុះកម្មសិក្សារបស់និស្សិតបច្ចេកទេស | - | ✓ | ✓ | ✓ | ✓ | ✓ |
| 💧 អាចសុំចូលរួមការទិញទំនិញជុំ ឬគម្រោងវិនិយោគរបស់សមាគម | - | ✓ | ✓ | ✓ | ✓ | ✓ |
| **ឯកសារការអនុវត្តល្អក្នុងវិស័យទឹកស្អាត*** | | | | | | |
| 💧 អាចសុំឯកសារច្បាប់ ឬបទដ្ឋាននានាទាក់ទងនឹងវិស័យទឹកស្អាត | - | - | ✓ | ✓ | ✓ | ✓ |
| 💧 អាចសុំបទដ្ឋាននៃការអនុវត្តការងារល្អ (SOP) | - | - | ✓ | ✓ | ✓ | ✓ |
| 💧 អាចសុំគំរូប្រតិបត្តិល្អសម្រាប់អ្នកផ្គត់ផ្គង់ទឹកស្អាត | - | - | ✓ | ✓ | ✓ | ✓ |
| 💧 របាយការណ៍សន្ទស្សន៍លទ្ធផលប្រចាំឆ្នាំ | - | ✓ | ✓ | ✓ | ✓ | ✓ |
| **សន្សំសំចៃប្រាក់*** | | | | | | |
| 💧 ការបញ្ចុះតម្លៃលើសេវាកម្ម ឬកម្មវិធីសមាគមផ្សេងៗ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| 💧 ការបញ្ចុះតម្លៃលើវគ្គបណ្តុះបណ្តាល | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| 💧 ការបញ្ចុះតម្លៃលើកន្លែងតាំងពិព័ណ៌រៀបចំដោយសមាគម | - | ✓ | - | - | ✓ | ✓ |
| 💧 ការបញ្ចុះតម្លៃលើការផ្សាយពាណិជ្ជកម្មតាមរយៈសមាគម | - | ✓ | - | - | ✓ | ✓ |

សំគាល់៖ * សម្រាប់តែអ្នកតំណាងរបស់សមាជិក ដែលបានបញ្ជាក់ឈ្មោះក្នុងលិខិតចាត់តាំងរបស់សមាជិកប៉ុណ្ណោះ។

** ចំនួនអ្នកតំណាងអាចកើនឡើងម្នាក់ រៀលរាល់ការបង់វិភាគទាន $១០០ លើសប្រាក់វិភាគទានអប្បបរមា ដែលបានកំណត់។

**ប្រការ ៦. ការបាត់បង់សមាជិកភាព** (យោងតាមប្រការ ១២ នៃលក្ខន្តិកៈសមាគម)

សមាជិករបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា អាចបាត់បង់សមាជិកភាពរបស់ខ្លួនដោយករណីណាមួយដូចខាងក្រោម៖

- ការដាក់លិខិតលាឈប់ជាលាយលក្ខណ៍អក្សរជូនក្រុមប្រឹក្សាភិបាល
- ខកខានក្នុងការបង់វិភាគទានដល់សមាគមក្នុងរយៈពេល៦ (ប្រាំមួយ) ខែ
- ទទួលមរណភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈការងារ ឬការប្រកាសក្ស័យធន ឬការរំលាយនីតិបុគ្គល

- បាត់បង់ប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណប្រកបអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលផ្តល់ឲ្យដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ពីមុនក្រសួងឧស្សាហកម្ម និងសិប្បកម្ម)
- មានជាប់ពិរុទ្ធដាក់ពន្ធនាគារពីបទមជ្ឈឹម ឬបទឧក្រិដ្ឋណាមួយ
- មានជំងឺវិបល្លាសស្មារតី ដែលមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមការសម្រេចដកសមាជិកភាពដោយកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល តាមរយៈសំឡេងអនុម័ត ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនកូរ៉ុមចូលរួម ២/៣ (ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល ក្នុងករណីដែលសមាជិកណាមិនគោរពតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចផ្សេងៗរបស់សមាគម ដែលបង្កឲ្យមានការខូចខាតដល់ផលប្រយោជន៍របស់សមាគម ទាំងមូល
- សមាគមត្រូវបានប្រកាសរំលាយ។

## ប្រការ ៧. ការធ្វើវិសោធនកម្ម

គោលការណ៍សមាជិកភាពនេះជាឯកសាររស់ នៅពេលសមាគមមានការរីកចម្រើនធំធាត់ស្ថានភាព វិស័យផ្គត់ផ្គង់ទឹកស្អាតមានការប្រែប្រួល តាមភាពចាំបាច់ប្រការមួយចំនួននៃគោលការណ៍នេះ អាចត្រូវបានធ្វើការកែប្រែ ដើម្បីឱ្យគោលការណ៍នេះ នៅតែមានប្រសិទ្ធិភាពក្នុងការជួយសមាគមអនុវត្តន៍ការងាររបស់ខ្លួន។

សមាគម ត្រូវពិនិត្យឡើងវិញនូវគោលការណ៍យ៉ាងតិចម្តងក្នុងរយៈពេលពីរឆ្នាំ និងធ្វើការកែប្រែតាមការចាំបាច់។ រាល់ការកែប្រែត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលរបស់សមាគម។

## ប្រការ ៨. សុពលភាព

បុគ្គលិកសមាគម និងសមាជិកសមាគមទាំងអស់ ត្រូវអនុវត្តតាមគោលការណ៍សមាជិកភាពនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខារបស់ ប្រធានក្រុមប្រឹក្សាភិបាលនេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី...15... ខែ...[illegible]... ឆ្នាំ...2022...

**ប្រធានក្រុមប្រឹក្សាភិបាល**

**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា**

Cambodian Water Supply Association

C.W.A

**ឡេង ខៀវ**

**<u>ចម្លងជូនៈ</u>**

- សមាជិកសមាគមទាំងអស់
- សមាជិកក្រុមប្រឹក្សាភិបាល
- បុគ្គលិក

**<u>ឧបសម្ព័ន្ធភ្ជាប់</u>**

ឧបសម្ព័ន្ធទី១៖ ពាក្យសុំចូលជាសមជិកអាជីព

ឧបសម្ព័ន្ធទី២៖ ពាក្យសុំចូលជាសមជិកគាំទ្រ

ឧបសម្ព័ន្ធទី៣៖ លិខិតចាត់តាំងអ្នកតំណាង

ឧបសម្ព័ន្ធទី១៖ ពាក្យសុំចូលជាសមជិកអាជីព

# ពាក្យសុំចូលជាសមាជិកអាជីព

| |
|---|
| រូបថត<br>៤x៦ |

ការសុំចូលជាសមាជិកអាជីពរបស់សមាគម គឺសម្រាប់តែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលបាន ប្រកាសអនុញ្ញាត ឬការព្រមព្រៀងឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។

ឈ្មោះស្ថានីយផ្គត់ផ្គង់ទឹកស្អាត៖.....................................................................................

ឈ្មោះបុគ្គល ឬក្រុមហ៊ុនដែលបានទទួលប្រកាសអនុញ្ញាត៖ ......................................................................

ឈ្មោះម្ចាស់ ឬប្រធានស្ថានីយផ្គត់ផ្គង់ទឹកស្អាត៖ ............................................ ភេទ.............. អាយុ.......................

អាសយដ្ឋានទំនាក់ទំនង៖.........................................................................................................................

......................................................................................................................................................

ទូរស័ព្ទខ្សែទី១៖................................... ខ្សែទី២៖................................ Email: ..................................................

ទីតាំងស្ថានីយផ្គត់ផ្គង់ទឹកស្អាតនៅ ភូមិ............................................. ឃុំ/សង្កាត់..........................................

ស្រុក/ក្រុង.......................................... ខេត្ត.......................................................។

ទទួលប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្ម លេខ៖...................................................... ចុះថ្ងៃទី........ ខែ......... ឆ្នាំ...............

ចំនួនភូមិក្នុងតំបន់សេវាកម្ម៖ ..................ភូមិ ចំនួនតំណចុងក្រោយ៖ ..............................តំណ

ខ្ញុំបាទ/នាងខ្ញុំជាម្ចាស់ ឬប្រធានស្ថានីយផ្គត់ផ្គង់ទឹកស្អាត ដូចដែលមានអាសយដ្ឋានរៀបរាប់ខាងលើ សុំចូលជា **សមាជិកអាជីព** របស់ **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ដើម្បីចូលរួមលើកស្ទួយវិស័យផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឲ្យមានការរីកចំរើន។ ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងអនុវត្តតាមលក្ខន្តិកៈសមាគម និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលសមាគម ហើយស្ម័គ្រចិត្តបង់ថ្លៃសមាជិកភាពប្រចាំឆ្នាំចំនួន $................ (..................................................................) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រុមអ្នកគ្រប់គ្រងសមាគម ទទួលយកស្ថានីយរបស់ខ្ញុំបាទ/នាងខ្ញុំ ជាសមាជិកអាជីព របស់ **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ដោយក្តីអនុគ្រោះ។

ធ្វើនៅ.............................. ថ្ងៃទី .......... ខែ......... ឆ្នាំ...........

**ហត្ថលេខា (និងត្រា)**

**ម្ចាស់ ឬប្រធានស្ថានីយផ្គត់ផ្គង់ទឹកស្អាត**

<u>ឯកសារភ្ជាប់</u>

- ☐ រូបថតម្ចាស់ ឬប្រធាន (៤គុណ៦) ចំនួន១សន្លឹក
- ☐ អត្តសញ្ញាណប័ណ្ណម្ចាស់ ឬប្រធាន ថតចំលង ចំនួន១ច្បាប់
- ☐ ប្រកាសអនុញ្ញាតថតចំលង ចំនួន១ច្បាប់
- ☐ លិខិតចាត់តាំងអ្នកតំណាង ចំនួន១ច្បាប់

ឧបសម្ព័ន្ធទី២៖ ពាក្យសុំចូលជាសមជិកគាំទ្រ

# ពាក្យសុំចូលជាសមាជិកគាំទ្រ

ការសុំចូលជាសមាជិកគាំទ្រ គឺបើកទូលាយចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានវិជ្ជាជីវៈ ឬចាប់អារម្មណ៍លើវិស័យទឹកស្អាតនៅកម្ពុជា ទាំងឡាយណាដែលមានបំណងចង់ចូលជាសមាជិកសាមញ្ញរបស់សមាគម។

រូបថត

៤x៦

ឈ្មោះបុគ្គល ឬនីតិបុគ្គលអ្នកស្នើសុំ៖.................................................................................................

ឈ្មោះអ្នកគ្រប់គ្រង ........................................ តួនាទី ............................................................. (បើជានីតិបុគ្គល)

អាសយដ្ឋានទំនាក់ទំនង៖.......................................................................................................................

.........................................................................................................................................................

ទូរស័ព្ទខ្សែទី១៖................................... ខ្សែទី២៖................................ Email: ................................................

ខ្ញុំបាទ/នាងជា ☐ បុគ្គលផ្ទាល់ ឬ ☐អ្នកតំណាងឲ្យក្រុមហ៊ុន ដែលមានអាសយដ្ឋានដូចបានរៀបរាប់ខាងលើ សុំចូលជា **សមាជិកគាំទ្រ** របស់**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ដើម្បីចូលរួមលើកស្ទួយវិស័យផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឲ្យមានការរីកចំរើន។ ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថា នឹងអនុវត្តតាមលក្ខន្តិកៈសមាគម និងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលសមាគម ហើយស្ម័គ្រចិត្តបង់ថ្លៃសមាជិកភាពប្រចាំឆ្នាំចំនួន................ (.....................................................)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រុមអ្នកគ្រប់គ្រងសមាគម ទទួលយកខ្ញុំបាទ/នាងខ្ញុំ ឬក្រុមហ៊ុនរបស់ខ្ញុំបាទ/នាងខ្ញុំជាសមាជិកគាំទ្ររបស់**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ដោយក្តីអនុគ្រោះ។

ធ្វើនៅ........................ថ្ងៃទី .......... ខែ......... ឆ្នាំ............

**ហត្ថលេខា(និងត្រា)**

<u>ឯកសារភ្ជាប់</u>

- ☐ រូបថតបុគ្គល ឬប្រធាន (៤គុណ៦) ចំនួន១សន្លឹក
- ☐ អត្តសញ្ញាណប័ណ្ណបុគ្គល ឬប្រធាន ថតចម្លង ចំនួន១ច្បាប់
- ☐ បណ្ណប៉ាតង់ថតចម្លង(ចំពោះក្រុមហ៊ុន) ចំនួន១ច្បាប់ ឬ
- ☐ លិខិតអនុញ្ញាតពីក្រសួងមហាផ្ទៃថតចម្លង(ចំពោះអង្គការ) ចំនួន១ច្បាប់
- ☐ លិខិតចាត់តាំងអ្នកតំណាង ចំនួន១ច្បាប់ (ចំពោះក្រុមហ៊ុន ឬអង្គការ)

# លិខិតចាត់តាំងអ្នកតំណាង

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ.................................................................. ភេទ.................. អាយុ.................

ជាម្ចាស់ ឬប្រធានស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រុមហ៊ុន ឬអង្គការ ........................................................................

មានអាសយដ្ឋានស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រុមហ៊ុន ឬអង្គការនៅ ..................................................................

..............................................................................................................................................

ទូរស័ព្ទទំនាក់ទំនងលេខ........................................................ និង Email: .................................................

បានស្ម័គ្រចិត្តបង់វិភាគទានប្រចាំឆ្នាំចំនួន..................... (...........................................................................)

សូមប្រកាសចាត់តាំងអ្នកតំណាងដូចមានរាយឈ្មោះខាងក្រោមក្នុងការទទួលបានអត្ថប្រយោជន៍នានាពីការចូលសមាជិកភាពរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាចាប់ពីថ្ងៃទី........ ខែ....... ឆ្នាំ............ រហូតដល់ពេលមានការជូនដំណឹងជាថ្មី។

| លរ | ឈ្មោះ | តួនាទី | លេខទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រុមអ្នកគ្រប់គ្រងសមាគម ទទួលយកបេក្ខភាពអ្នកតំណាងរបស់ខ្ញុំបាទ/នាងខ្ញុំដោយក្តីអនុគ្រោះ។

ធ្វើនៅ......................ថ្ងៃទី .......... ខែ......... ឆ្នាំ............

**ហត្ថលេខា(និងត្រា)**

ឯកសារភ្ជាប់

- ☐ រូបថតអ្នកតំណាង ៤គុណ៦ ចំនួន១សន្លឹកម្នាក់
- ☐ អត្តសញ្ញាណប័ណ្ណអ្នកតំណាងថតចម្លង ចំនួន១ច្បាប់ម្នាក់